# អ្វីដែលអ្នកគួរយល់ដឹងអំពី ប្រឹព ( PrEP )

# (PRE-EXPOSURE PROPHYLAXIS)

## ប្រឹព (PrEP) ជាអ្វី?

ប្រឹព (PrEP មកពីពាក្យ Pre-exposure prophylaxis) ជាថ្នាំប្រើមួយគ្រាប់ក្នុងមួយថ្ងៃ  ហើយបើប្រើតាមវេជ្ជបញ្ជា វាជួយការពារអ្នកពីការឆ្លងជំងឺ HIV ។ ថ្នាំ ប្រឹព (PrEP) មានជាគ្រាប់ និងថ្នាំចាក់ ។ ថ្នាំ ប្រឹព ការពារអ្នកដែលមិនមានមេរោគ HIV ពីការឆ្លងមេរោគ HIV ពីដៃគូរួមភេទដែលមានមេរោគ HIV  ឬការពារការឆ្លងពីការប្រើឧបករណ៍សម្រាប់ចាក់គ្រឿងញៀនរួមគ្នាជាមួយដៃគូដែលមានផ្ទុកមេរោគ HIV។



## តើថ្នាំ ប្រឹព (PrEP) ដំណើការយ៉ាងដូចម្តេច ?



មេរោគ HIV វាទៅវាយប្រហារប្រព័ន្ធការពាររាងកាយក្នុងខ្លួនមនុស្ស ដែលជាប្រព័ន្ធជួយការពាររាងកាយពីមេរោគនានា ។ ដំណើរការរបស់ ថ្នាំ PrEP គឺទៅបង្កើតជារបាំងការពារមេរោគ HIV កុំអោយវាយប្រហារកោសិកាល្អរបស់អ្នក ។ បើមិនប្រើថ្នាំនេះអោយបានត្រឹមត្រូវតាមវេជ្ជបញ្ជា  វាមិនមានប្រសិទ្ធិភាពទេ ។

## អ្វីដែលអ្នកត្រូវដឹង

អ្នកត្រូវធ្វើតេស្តរកមេរោគ HIV មុននឹងប្រើថ្នាំ  PrEP ។ ពេលអ្នកកំពុងប្រើថ្នាំ PrEP អ្នកត្រូវ ជួបគ្រូពេទ្យជាប្រចាំ ដើម្បីពិនិត្យសុខភាព ធ្វើតេស្តរកមេរោគ HIV/STI ពិនិត្យឈាម និងបន្តរប្រើថ្នាំតាមវេជ្ជបញ្ជា ។



longbeach.gov/HIVcare

LONGBEACH
HEALTH & HUMAN SERVICES

# អ្វីដែលអ្នកគួរយល់ដឹងអំពី ប្រ៊ើព (PrEP) (PRE-EXPOSURE PROPHYLAXIS)

## តើខ្ញុំអាចប្រើថ្នាំប្រ៊ើព **PrEP** បានឬទេ ?

ថ្នាំ PrEP កាត់បន្ថយហានិភ័យនៃការឆ្លងមេរោគ HIV ពីការរួមភេទ នៅពេលប្រើតាមវេជ្ជបញ្ជា ។ ថ្នាំ PrEP ក៏អាចប្រើក្នុងពេលដែលអ្នកកំពុងប្រើថ្នាំអរម៉ូនភេទផងដែរ។ ប្រសិនបើអ្នកបារម្ភពីការឆ្លងមេរោគ HIV សូមពិគ្រោះយោបល់ជាមួយវេជ្ជបណ្ឌិតថាតើអ្នកអាចប្រើថ្នាំនេះបានទេ។





**ពិគ្រោះយោបល់** ជាមួយគ្រូពេទ្យ អំពីសុខភាពផ្លូវភេទ **របស់អ្នក**

## សំរាប់ព័ត៌មានបន្ថែម

សំរាប់ការណាត់ជួបអ្នកជំនួយចំពោះថ្នាំ PrEP សូមទូរស័ព្ទមកលេខ **562.570.4396** ឬផ្ញើសារមកលេខ **562.964.5369**

**longbeach.gov/HIVcare**

## កម្មវិធីជំនួយ

នាយកដ្ឋានសុខាភិបាលរបស់សាលាក្រុងឡុងប៊ិចមានកម្មវិធីជំនួយថ្នាំ ប្រ៊ើព (PrEP) ដល់អ្នកដែលត្រូវការជំនួយបង់ថ្លៃថ្នាំ ឬអ្នកដែល មិនមានធានាសុខភាព ឬ មានធានាសុខភាពកំរិតទាប ។ សំរាប់ព័ត៌មានបន្ថែម៖ **longbeach.gov/HIVcare**